# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
លេខាធិការដ្ឋាន
លេខ ៣៧៥ ឧ.ក្រ.ច ២០០២

## លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**សូមជម្រាបចក**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង**

**លោកព្រះរាជអាជ្ញាគ្រប់អយ្យការខេត្ត-ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការឃុំខ្លួនពិរុទ្ធជនលើសថេរវេលាកំណត់ នៃច្បាប់ ។

លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សូមជម្រាបឯកឧត្តម អស់លោក លោកស្រី ក្រោយពីបានចុះទៅក្តាប់ស្ថានភាពការងារនៅគ្រប់តុលាការ និងមន្ទីរឃុំឃាំងទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រុមការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានសង្កេតឃើញថាពិរុទ្ធជនមួយចំនួនធំពិសេសនៅរាជធានីភ្នំពេញ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នលើសថេរវេលាកំណត់ នៃបញ្ញត្តិច្បាប់ពី ៧ ខែ ទៅ ១ ឆ្នាំ ។

ការឃុំខ្លួនលើសថេរវេលានេះ មានកត្តាជាច្រើនដែលឆ្លើយដាក់គ្នារវាងតុលាការ និងប្រធានមន្ទីរឃុំឃាំងខ្លះថាមកពីតុលាការឃុំលើសដោយខ្លួនឯង ខ្លះថាមកពីពន្ធនាគារគ្មានមធ្យោបាយដឹកជញ្ជូនពិរុទ្ធជនមកសវនាការតាមការកំណត់របស់តុលាការ បណ្តាលអោយតុលាការលើកពេលសវនាការជំនុំជម្រះជាច្រើនលើក ខ្លះថាលុះត្រាតែតុលាការផ្តល់ថ្លៃឈ្នួលដឹកជញ្ជូនពិរុទ្ធជនមកសវនាការ ទើបមន្ទីរឃុំឃាំងមានលទ្ធភាពដឹកជញ្ជូនតាមការកំណត់ ។ ម្យ៉ាងទៀតនៅខេត្តមួយចំនួន ការដឹកជញ្ជូនពិរុទ្ធជនមកសវនាការមានលក្ខណៈមិនសមរម្យខ្វះសុវត្ថិភាពប៉ះពាល់ដល់សិទ្ធិ និងកិត្តិយសបុគ្គលផង ។

ដើម្បីអោយមានដំណើរការល្អនូវបញ្ហាដូចពោលខាងលើ លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំណូមពរ ៖

-សុំឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាចាត់ឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ប្រគល់ឱ្យគ្រប់មន្ទីរឃុំឃាំងពិរុទ្ធជននូវរថយន្តសមស្របសម្រាប់ដឹកពិរុទ្ធជនទាំងអស់នោះមកកាន់តុលាការតាមដីការបស់តុលាការ ។

-សុំអោយលោកព្រះរាជអាជ្ញា នៃអយ្យការគ្រប់ខេត្ត-ក្រុង តាមដានយ៉ាងល្អិតល្អន់អំពីពិរុទ្ធជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្ន ឬ អោយនៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីឱ្យដំណើរការសវនាការជំនុំជម្រះប្រព្រឹត្តទៅដោយគ្មានភាពមិនប្រក្រតី ។

-មិនគប្បីឱ្យមានជាបន្តទៀតនូវការដឹកជញ្ជូនពិរុទ្ធជនមកសវនាការជំនុំជម្រះតាមម៉ូតូឌុប ឬរ៉ឺម៉កម៉ូតូ ដែលជាការបំពានទៅលើជំពូកទី១ ចំនុចទី ៤៥ (១) នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោសអនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទី១ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការប្រព្រឹត្តលើអ្នកទោស ដែលបានប្រារព្ធនៅទីក្រុងហ្សឺណែវឆ្នាំ១៩៥៥ ហើយនិងបានទទួលការយល់ព្រមអោយប្រើប្រាស់ពីក្រុមប្រឹក្សាផ្នែកសេដ្ឋកិច្ច

និងសង្គមនៃអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ ៦៦៣C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ ហើយនិងសេចក្តីសំរេចលេខ ២០៧៦ (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ ដែលបានកំណត់ថា នៅពេលដឹកជញ្ជូនអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀតនោះ ធ្វើយ៉ាងណាកុំឱ្យសាធារណជនឃើញច្រើនពេក ហើយវិធានការការពារសមស្របនានាត្រូវតែយកមកអនុវត្ត ដើម្បីការពារអ្នកទោសឱ្យផុតពីការត្មះតិះដៀលការលេចមុខជាសាធារណៈ ទោះជាតាមទ្រង់ទ្រាយបែបណាក៏ដោយ ។

-ចំពោះលោកចៅក្រមស៊ើបអង្កេត ត្រូវយកចិត្តទុកដាក់ស៊ើបអង្កេតប្រមូលភស្តុតាងឱ្យបានមូលសព្វគ្រប់មុនរយៈពេលកំណត់នៃច្បាប់ដើម្បីតំណាងអយ្យការមានលទ្ធភាពពិនិត្យ និងធ្វើដីកាសន្និដ្ឋានស្ថាពរ ជូនរឿងទៅជម្រះ ។

-ចៅក្រមជំនុំជម្រះ ត្រូវកំណត់ពេលសវនាការជំនុំជម្រះឱ្យបានត្រឹមត្រូវជៀសវាងការឃុំខ្លួនជាបណ្តោះអាសន្នលើសការកំណត់នៃច្បាប់ ។

-ចំពោះមន្ទីរឃុំឃាំង នៃគ្រប់ខេត្ត-ក្រុង គួរតែមានកន្លែងឃុំខ្លួនបណ្តោះអាសន្នសមរម្យដាច់ដោយឡែកពីពន្ធនាគារ ពីព្រោះពិរុទ្ធជន ឬជនល្មើស ពុំមែនជាទណ្ឌិតទេ ។

សេចក្តីដូចជម្រាបខាងលើ សូមឯកឧត្តម អស់លោក លោកស្រី មេត្តាជ្រាបនិងពិនិត្យលទ្ធភាពចាត់ការតាមការគួរ ។

សូម ឯកឧត្តម អស់លោក លោកស្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២

**ឡៅ មួន**

<u>ចម្លងជូន</u>

- ឯកឧត្តមអភិបាលខេត្ត-ក្រុង
- លោកស្នងការខេត្ត-ក្រុង
- លោកប្រធានមន្ទីរកែប្រែព្រៃសទី១ ម១ និងម២
- លោកប្រធានមន្ទីរឃុំឃាំងខេត្ត-ក្រុង

-ដើម្បីជ្រាប -ឯកសារ